# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ៧០១.កយ.ព្រទ-២០០៥

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោកប្រធានតុលាការក្រុងភ្នំពេញ

លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

**កម្មវត្ថុ:** ស្ដីពីសំណុំរឿងព្រហ្មទណ្ឌទាក់ទងនឹងករណីជួញដូរមនុស្សនៅតុលាការក្រុងភ្នំពេញ ។

**យោង:** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

-អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

-ច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស

-កម្មវិធីនយោបាយទាំង ៧៣ ចំណុច និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា

តបតាមកម្មវត្ថុនិងយោងខាងលើ ក្រសួងយុត្តិធម៌សូមជម្រាបលោកជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ និងចាត់វិធានការយ៉ាងខ្លាំងក្លា ពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងសញ្ចារកម្មដោយបានដាក់បញ្ហានេះបញ្ចូលទៅក្នុងកម្មវិធីនយោបាយ៧៣ ចំណុច និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងធានា ការពារតាមផ្លូវច្បាប់ប្រកបដោយយុត្តិធម៌ ព្រមទាំងការពារស្ត្រីឱ្យរួចផុតពីអំពើហឹង្សាក្នុងគ្រួសារនិងអំពីការជួញដូរផ្លូវភេទ ហើយរាជរដ្ឋាភិបាលកម្ពុជាបានប្ដូរផ្ដាច់ដាក់ចេញនូវវិធានការចាំបាច់គ្រប់បែបយ៉ាងដើម្បីទប់ស្កាត់អំពើគាបសង្កត់និងការធ្វើអាជីវកម្មគ្រប់រូបភាពទៅលើកុមារ ការជួញដូរកុមារ ព្រមទាំងអំពើអាណាចារ្យ និងអសីលធម៌ផ្សេងៗទៀត ទៅលើកុមារនៅតាមសហគមន៍ ។

ជាក់ស្ដែងរាជរដ្ឋាភិបាលបាននឹងកំពុងចាត់វិធានការបង្កា-បង្ក្រាប និងបិទទ្វារនូវទីតាំងជួញដូរផ្លូវភេទនិងសញ្ចារកម្មធំៗជាច្រើនកន្លែង ហើយចាប់បញ្ជូនជនល្មើសទៅកាន់តុលាការជាច្រើនករណី បច្ចុប្បន្នសំណុំរឿងទាំងនេះត្រូវបានតុលាការក្រុងភ្នំពេញចាត់ការជាសមត្ថកិច្ច ។

អាស្រ័យហេតុនេះ ដើម្បីការពារប្រយោជន៍ច្បាប់ក៏ដូចជាការលើកកម្ពស់កិត្យានុភាពរបស់ជាតិ ក្នុងឆាកអន្តរជាតិឱ្យស្របតាមការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្រសួងសូមឱ្យលោកយកចិត្តទុកដាក់ចាត់ការសំណុំរឿងករណីជួញដូរមនុស្ស និងសញ្ចារកម្មនេះឱ្យបានម៉ឺងម៉ាត់ កាត់ក្ដីប្រកបដោយយុត្តិធម៌ និងមានតម្លាភាពហើយផ្ដន្ទាទោសជនល្មើសឱ្យធ្ងន់សមល្មមនឹងសារជាតិ ដែលគួរឱ្យស្អប់ខ្ពើម ចំពោះបទល្មើសនៃការជួញដូរមនុស្សទៅតាមច្បាប់កំណត់ ទន្ទឹមនឹងនេះដែរក្រសួងសូមឱ្យលោក ចាត់វិធានការបន្ថែមឱ្យបានហ្មត់ចត់មានប្រសិទ្ធិភាពទៅតាមនីតិវិធីច្បាប់លើសំណុំរឿងព្រហ្មទណ្ឌពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស និងសញ្ចារកម្មចំនួន ០៧ ករណីដូចខាងក្រោម ៖

១-សំណុំរឿងព្រហ្មទណ្ឌលេខ ៩៦៧ ចុះថ្ងៃទី២០-០៥-២០០៤ របស់តុលាការក្រុងភ្នំពេញ

២-សំណុំរឿងព្រហ្មទណ្ឌលេខ ១០៩៨ ចុះថ្ងៃទី០៩-០៦-២០០៤ របស់តុលាការក្រុងភ្នំពេញ

៣-សំណុំរឿងព្រហ្មទណ្ឌលេខ ២១៨៨ ចុះថ្ងៃទី១០-១១-២០០៤ របស់តុលាការក្រុងភ្នំពេញ

៤-សំណុំរឿងព្រហ្មទណ្ឌលេខ ១៧៤៦ ចុះថ្ងៃទី៣០-០៩-២០០៤ របស់តុលាការក្រុងភ្នំពេញ ។

៥-សំណុំរឿងព្រហ្មទណ្ឌលេខ ២៧០ ចុះថ្ងៃទី២១-០១-២០០៥ របស់តុលាការក្រុងភ្នំពេញ
៦-សំណុំរឿងព្រហ្មទណ្ឌលេខ ១៦០៤ ចុះថ្ងៃទី២៣-០៨-២០០៤ របស់តុលាការក្រុងភ្នំពេញ
៧-សំណុំរឿងព្រហ្មទណ្ឌលេខ ២០២០ ចុះថ្ងៃទី២២-១០ -២០០៤ របស់តុលាការក្រុងភ្នំពេញ ។

សូមលោកទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលាក្រុងភ្នំពេញ
-តុលាការកំពូល
-សាលាឧទ្ធរណ៍
”ដើម្បីជូនជ្រាប ”
-ឯកសារ -កាលប្បវត្តិ